








# ឥទ្ធិពលនៃព័ត៌មាន

## ដំណឹងក្លែងក្លាយ

## និង

## ព័ត៌មានមិនពិត

រៀបចំដោយ៖ នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន

ដោយ៖ សេន សុនី ០១២ ៥៦៧ ១១៩

# ការទស្សនាបទយការណ៍ស្ដីពី ព័ត៌មានមិនពិត



# មាតិកា

I. ឥទ្ធិពល និងតួនាទីព័ត៌មានជាវិជ្ជមាន

II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត

III. ផលប៉ះពាល់

IV. ការចូលរួមការពារ និងទប់ស្កាត់

(គិតត្រឹម ២២ តុលា ២០២៣)

- កម្ពុជាមានអ្នកប្រើប្រាស់ internet ជាង ១៦លាននាក់ ជិត១០០% នៃប្រជាជន

- បច្ចុប្បន្ននៅកម្ពុជា មានសារព័ត៌មានបោះពុម្ពផ្សាយបានចុះបញ្ជីនៅក្រសួងព័ត៌មាន មានចំនួនប្រមាណ ៥០០ អាជ្ញាបណ្ណ,

- ✓ វិទ្យុFM មានជាង ២២១ ស្ថានីយ៍ នៅទូទាំងប្រទេស,
- ✓ ស្ថានីយ៍ទូរទស្សន៍ មាន ២១ ប៉ុស្តិ៍
- ✓ ទូរទស្សន៍ខ្សែកាបមានជាង ៩០ ប៉ុស្តិ៍,
- ✓ សារព័ត៌មានអនឡាញមានចំនួន ជាង ៩០០ អាជ្ញាបណ្ណ

# I. ឥទ្ធិពល និងតួនាទីព័ត៌មានជាវិជ្ជមាន







១- សារព័ត៌មាន ត្រូវបានគេចាត់ទុកថាជា**អ្នកនាំពាក្យ**យ៉ាងសំខាន់

២-សារព័ត៌ជា **អ្នកជួយកសាងសមត្ថភាព** ក្នុងការគិត ពិចារណា វិនិច្ឆ័យ

៣-សារព័ត៌មានគឺ ជាអ្នកដកស្រង់យកនូវបញ្ហា និង **ឥថភាព ក្នុងសង្គម**

# I. ឥទ្ធិពល និងតួនាទីព័ត៌មានជាវិជ្ជមាន



៤- សារព័ត៌មានជាកន្លែងដែលផ្តល់ **ចំណេះដឹង** យ៉ាងសម្បូរបែប

៥-ព័ត៌មានជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអប់រំប្រជាជនឱ្យបាន **យល់ដឹងពីការប្រែប្រួលនៃដំណើររបស់សង្គម** ហើយត្រៀមខ្លួនឱ្យស្របទៅតាមស្ថានភាពរបស់សង្គម



៦-បើគ្មានព័ត៌មាន មនុស្សគ្រប់គ្នាប្រហែលជាមិនអាចស្គាល់ភាពជឿនលឿន ឬដឹងពីដំណឹង និងហេតុការណ៍នានានៅក្នុងសង្គមនោះទេ

# II. ដំណឹងក្លែងក្លាយ និង ព័ត៌មានមិនពិត




«ដំណឹងក្លែងក្លាយ,ព័ត៌មានក្លែងបន្លំ,ព័ត៌មានទាន់ច្រឡំ និងព័ត៌មានបំភ្លៃ»តើមានន័យខុសគ្នាដូចម្តេច?

# II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិ~



# II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត

rnk.gov.kh
https://rnk.gov.kh › index.php · Translate this page

**វិដេអូ ៖ សិក្ខាសាលាស្តីពី«ផលប៉ះពាល់នៃដំណឹងក្លែងក្លាយនិង ...**

វិដេអូ ៖ សិក្ខាសាលាស្តីពី«ផលប៉ះពាល់នៃ**ដំណឹងក្លែងក្លាយ**និងដំ...
សារព័ត៌មានកាន់តែយល់ច្បាស់ពីតម្លៃវិជ្ជាជីវៈរបស់ ...

VAYO FM Radio
https://vayofm.com › news › detail · Translate this page

**ដំណឹងក្លែងក្លាយពិតជាបង្កផលប៉ះពាល់មិន**

ថ្លែងក្នុងពិធីបើកវេទិកា...
ឆ្នាំ២០២១ ...

Scribd
https://www.scribd.com › document › វិជ្ជាជីវៈសារព័ត៌មាន...

**វិជ្ជាជីវៈសារព័ត៌មាន "ដំណឹងក្លែងក្លាយ" និង**

terms-use-ccbysa-en)។ ...
ក្លែងក្លា យ" និងព័ត៌មានមិនពិត;

**ក្រសួងព័ត៌មាន ឱ្យដឹងថា ក្នុងពេល៨ខែ ឆ្នាំ២០២១នេះ ក្រសួងបានរកឃើញករណីផ្សាយពាក់ព័ន្ធនឹងដំណឹងក្លែងក្លាយ ព័ត៌មានមិនពិត ញុះញង់ បំពុលសង្គម និងប្រមាថថ្នាក់ដឹកនាំ ចំនួន១ ០៦១ករណី បើធៀបនឹងឆ្នាំ២០២០ អំពើល្មើសនេះមានចំនួនប្រហាក់ប្រហែលគ្នា។**

Facebook · បណ្តាញព័ត៌មានថ្មី
2 years ago

**ក្រសួងព័ត៌មាន រៀបចំសិក្ខាសាលាស្តីពី “ផលប៉ះពាល់ នៃ ...**




ក្រសួងព័ត៌មាន រៀបចំសិក្ខាសាលាស្តីពី "ផលប៉ះពាល់ នៃ**ដំណឹងក្លែងក្លាយ** និង ដំណោះស្រាយរបស់រដ្ឋាភិបាល"

RFI
https://www.rfi.fr › cambodia › fak... · Translate this page

**ព័ត៌មានក្លែងក្លាយ នៅលើបណ្តាញសង្គម**

Mar 5, 2017 — នៅក្នុងជីវភាពប្រចាំថ្ងៃ មិនចាំបាច់និយាយដល់ព័ត៌មានក្លែងក្លាយឬ**ដំណឹង**ចចាមអារាមអ្វីណាទេ គ្រាន់តែព័ត៌មានពិត ...

## II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត

(ប្រភពពីកាសែតថ្មីៗ ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២០ ម៉ោង ៧:២៩នាទីព្រឹក)
ក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័តឲ្យប្រើពាក្យ«ដំណឹងក្លែងក្លាយ,ព័ត៌មានក្លែងបន្លំ,ព័ត៌មានភាន់ច្រឡំ និងព័ត៌មានបំភ្លៃ» ដោយបានពន្យល់ពាក្យទាំងអស់នេះដូចខាងក្រោម៖

### ១. «ដំណឹងក្លែងក្លាយ» Fake News

មានន័យថា **សាច់រឿងមិនពិត**ដែលត្រូវបានគេ**ប្រឌិត ឬកែច្នៃ**ជាព័ត៌មានទៅផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិត ឬ បណ្ដាញសារព័ត៌មានផ្សេងៗ ក្នុងបំណង**<u>កេងចំណេញនយោបាយ អាជីវកម្ម និងធ្វើឲ្យជ្រួលច្របល់ក្នុងសង្គម</u>**

# II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត

## ២«ព័ត៌មានក្លែងបន្លំ» Disinformation

មានន័យថា **ប្រភពព័ត៌មានមិនពិតដែលបានបង្កើតឡើង** ហើយយកទៅផ្សព្វផ្សាយ ឬចែកចាយដោយចេតនាដើម្បី **បំភាន់ ឬបោកប្រាស់សាធារណជន** ក្នុងគោលបំណង**បង្កផលប៉ះពាល់ដល់ជនណាម្នាក់ អង្គការណាមួយ ឬប្រទេសណាមួយ**

# II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត

## ៣. «ព័ត៌មានតាន់ច្រឡំ» Misinformation

មានន័យថា **ប្រភេទព័ត៌មានមិនពិតដែលត្រូវបានគេផ្សព្វផ្សាយ ឬចែករំលែកតៗគ្នា**ដោយចេតនា ឬអចេតនា ធ្វើឲ្យមានការយល់ច្រឡំ ហើយជួនកាលអ្នកចែករំលែកមិនដឹងច្បាស់ពីប្រភពនៃព័ត៌មានដែលខ្លួនទទួលបាន**ដោយគ្មានបំណងធ្វើឲ្យខូចខាត ឬប៉ះពាល់ផលប្រយោជន៍បុគ្គល ស្ថាប័ន ឬប្រទេសណាមួយឡើយ**

# II. ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត

## ៤. «**ព័ត៌មានបំភ្លៃ**» Malinformation

មានន័យថា **ប្រភេទព័ត៌មានមិនពិតដែលត្រូវបានគេកែច្នៃពីព័ត៌មានពិត** ហើយត្រូវបានគេយកមកផ្សព្វផ្សាយ ឬចែកចាយក្នុង**ចេតនាធ្វើឲ្យប៉ះពាល់ផលប្រយោជន៍កិត្តិយសបុគ្គល អង្គការ ស្ថាប័ន ឬប្រទេសណាមួយ**

# III. ផលប៉ះពាល់នៃ

«ដំណឹងក្លែងក្លាយ,

ព័ត៌មានក្លែងបន្លំ,

ព័ត៌មានទាន់ច្រឡំ

និងព័ត៌មានបំភ្លៃ






# III. ផលប៉ះពាល់

- ព័ត៌មានក្លែងក្លាយ កំពុងតែវាយលុកសង្គមខ្មែរ
- បណ្តាញសង្គមត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយ ព័ត៌មានក្លែងបន្លំ កាន់តែសាយភាយលឿនរហ័ស បណ្តាលឲ្យតានតឹង និងជ្រួលច្របល់
- ក្នុងបរិបទនេះ ការចែកចាយព័ត៌មានរបស់ពលរដ្ឋក្នុងជីវិតប្រចាំថ្ងៃ ពិសេសនៅលើបណ្តាញសង្គម គួរតែត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្នជាទីបំផុត

# III. ផលប៉ះពាល់នៃ

- ដំណឹងក្លែងក្លាយ និងព័ត៌មានមិនពិត បង្កផលប៉ះពាល់អវិជ្ជមាន លើនយោបាយ សេដ្ឋកិច្ច សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម អំពើឆបោក ការគំរាមកំហែង .....

- វាអាចធ្វើឱ្យសហគមន៍ និងសង្គមជាតិមានភាពច្របូកច្របល់ តាមរយៈការបង្កឲ្យមានការរើសអើងជាតិសាសន៍ ការបាត់បង់ទំនុកចិត្តមកលើស្ថាប័នសាធារណៈ ការលួចទិន្នន័យផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ និងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាដើម

# III. ផលប៉ះពាល់នៃ

- ដំណឹងក្លែងក្លាយ បង្កឱ្យមានការបែកបាក់សាមគ្គីភាព សន្តិសុខរបស់ប្រទេសចុះខ្សោយ ធ្វើឱ្យមានការមិនទុកចិត្តគ្នា ការបែងចែកវណ្ណៈ និងអំពើហិង្សាក្នុងចំណោមប្រជាជន។ លើសពីនេះ បានធ្វើ ឱ្យប៉ះពាល់ដល់ទំនុកចិត្ត របស់ប្រជាពលរដ្ឋ ចំពោះសារព័ត៌មាន។

- ដំណឹងក្លែងក្លាយ ក្នុងទម្រង់ជាពាក្យស្អប់ខ្ពើម ការនិទានប្រឌិត ការបរិហារកេរ្តិ៍ និងការញុះញង់ មានការកើនឡើងយ៉ាងខ្លាំងក្នុងអំឡុង ពេលនៃការរីករាលដាល នៃជំងឺកូវីដ១៩ក្នុងសហគមន៍។

# III. ផលប៉ះពាល់នៃ

- ក្នុងពេលជំងឺរាតត្បាតសកល យើងសង្កេតឃើញថា ព័ត៌មានមិនពិត មានការរីករាលដាល លឿនជាងមេរោគឆ្លងទៅទៀត។ សម្ដេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅដើមឆ្នាំ២០២០ បានបញ្ជាក់ថា «កូវីដ១៩ គឺជាជំងឺ ដ៏កាចសាហាវ ប៉ុន្តែព័ត៌មានក្លែងក្លាយ គឺសាហាវជាងជំងឺកូវីដ១៩ ទៅទៀត»។

# IV. ការចូលរួមការពារ និង ទប់ស្កាត់

# IV. ការចូលរួមការពារ និងទប់ស្កាត់

- **ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត ឬដំណឹងក្លែងក្លាយ** គឺជា **និន្នាការសកល** ដែលបណ្តារដ្ឋនៅលើសកលលោក បាននិងកំពុងយកចិត្តទុកដាក់ខ្ពស់
- សម្រាប់អ្នកដែលចូលចិត្តចែករំលែកបន្តព័ត៌មាន អមដោយការបញ្ចេញមតិ  នេះគឺជាសិទ្ធិរបស់បុគ្គលម្នាក់ៗ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ។ ប៉ុន្តែ **មុនពេលប្រតិកម្មលើព័ត៌មាន** អ្នកប្រើប្រាស់បណ្តាញសង្គមត្រូវច្បាស់ខ្លួនឯងជាមុនសិនថា ព័ត៌មាននោះគឺជារឿងពិត។ ព្រោះក្នុងករណីដែលវាជាព័ត៌មានមិនពិត អ្នកដែលចែករំលែកព័ត៌មាននោះ **អាចរងការប្តឹងផ្តល់តាមផ្លូវតុលាការ**។

# IV. ការចូលរួមការពារ និងទប់ស្កាត់




ខ្លឹមសារដកស្រង់ពីលោក ប្រាក់ វ៉ាន់ដា (ឡាយោ) អនុប្រធានអនុគណៈកម្មការតាមដានមាតិកាផ្សាយ និងកំណត់អត្តសញ្ញាណ នៃគណៈកម្មការតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ក្រសួងព័ត៌មាន

# IV. ការចូលរួមការពារ និងទប់ស្កាត់

## របៀបសម្គាល់ ដំណឹងក្លែងក្លាយ លើបណ្តាញផ្សព្វផ្សាយសង្គម

១. សូមពិនិត្យមើល**កាលបរិច្ឆេទចេញផ្សាយ** និង**ភូមិសាស្ត្រ**ដែលព្រឹត្តិការណ៍កើតឡើង (**ពេលណា កន្លែងណា នរណាធី**)

២. សូមមើល**ប្រភពព័ត៌មាន** តើអ្នកនិយាយក្នុងរឿងជានរណា? គាត់ជាអ្នកដែលទាក់ទិននឹងខ្លឹមសាររឿងឬទេ? (នរណាអះអាង ហើយបានអ្វីយកមកអះអាង)

៣. **អង្គភាពដែលចេញផ្សាយជាសារព័ត៌មានប្រភេទណា**? ឬ គណនីបណ្តាញសង្គមនោះអ្នកប្រើកន្លងមករបៀបណា?

៤. តើមានបណ្តាសារព័ត៌មានដទៃផ្សេងទៀតចេញផ្សាយពីរឿងនោះដែរឬទេ? (**ចូលរកមើលផ្ទៀងផ្ទាត់ជាមួយអង្គភាពព័ត៌មានដែលចេញផ្សាយប្រចាំថ្ងៃ**)

# IV. ការចូលរួមការពារ និងទប់ស្កាត់




៥. គណនីបណ្តាញសង្គមនោះបង្កើតឡើងយូរមកហើយ ឬទើបបង្កើត?

៦. **ស្ថាប័នពាក់ព័ន្ធមានចេញប្រកាសព័ត៌មាន ឬជូនដំណឹងអ្វីទេនៅលើរឿងនោះ**?

៧. ឯអ្នកសារព័ត៌មានវិញក៏កុំព្យាយាមចាប់មុំ(ច្បិចយកផ្នែកណាមួយនៃរឿងរ៉ាវ) យកមកចុះផ្សាយដោយមានខ្លឹមសារមិនគ្រប់ជ្រុងជ្រោយ នាំឲ្យមានការភាន់ច្រឡំ ឬប្រើរូបភាពចាស់ខុសពីព្រឹត្តិការណ៍ដើម

៨. **កុំចែកចាយឆាប់រហ័សពេក បើមិនបានផ្ទៀងផ្ទាត់ជាមុន។**

# IV. ការចូលរួមការពារ និងទប់ស្កាត់

## សញ្ញាព្រមាននៃមាតិកាក្លែងក្លាយ ឬបំភាន់

- ខុសពេលវេលា ឬទីកន្លែង → រៀនរបៀបកំណត់ទីតាំងភូមិសាស្ត្រ
- មាតិការូបភាពបោកបញ្ឆោត → រៀនផ្ទៀងផ្ទាត់ព័ត៌មានជាមួយប្រភពដទៃទៀត
- មាតិកាដែលប្រឌិតឡើង →រៀនសម្គាល់វិភាគស្រមោលក្នុងរូប

## សួរសំណួរខ្លួនឯង នៅពេលផ្ទៀងផ្ទាត់៖

- តើមាតិកានេះ ជាមាតិកាដើមមែនទេ?
- ឬមាតិកានេះ
  ត្រូវបានគេផ្សែផ្សំយកចេញពីសេច
  កក្តីរាយការណ៍មុន និងកែសម្រួលក្នុងលក្ខណៈមួយ ដែលនាំឱ្យមានការភ័ន្តច្រឡំឬទេ?
- តើមាតិកានេះ ត្រូវបានគេកែកុន ដោយបច្ចេកវិទ្យាឌីជីថលដែរឬទេ?
- តើយើងអាចបញ្ជាក់អំពីពេលវេលា និងទីកន្លែងនៃការថតរូបភាព/វីដេអូ
  ដោយប្រើទិន្នន័យមេតា (metadata) បានដែរឬទេ?
- តើយើងអាចបញ្ជាក់អំពីពេលវេលា និងទីកន្លែងនៃការថតរូបភាព/វីដេអូ
  ដោយប្រើតម្រុយដែលអាចមើលឃើញ នៅក្នុងមាតិកានោះបានដែរទេ?

# IV. ការចូលរួមការពារ និងទប់ស្កាត់

- ក្រៅពីការ**ការពារខ្លួនឯង**មិនឲ្យរងគ្រោះព្រោះព័ត៌មានក្លែងក្លាយ អ្នកប្រើបណ្ដាញសង្គមក៏អាចរួមចំណែកក្នុងការទប់ស្កាត់កុំឲ្យវារីករាលដាលវែងឆ្ងាយបានដែរ ដោយ **ដាស់តឿនអ្នកជុំវិញខ្លួន** ដែលចូលចិត្តចែករំលែកព័ត៌មាន។

- នៅក្នុងបណ្ដាញសង្គមហ្វេសប៊ុក អ្នកប្រើប្រាស់ក៏អាច**រាយការណ៍អំពីព័ត៌មានក្លែងក្លាយដែរ** ដែលប្រព័ន្ធនេះក្រុមហ៊ុនហ្វេសប៊ុកបានដាក់ឲ្យដំណើរការតាំងពីចុងឆ្នាំ២០១៦មកម្ល៉េះ

# IV. ការចូលរួមការពារ និងទប់ស្កាត់

- សរុបមកវិញ នៅក្នុងបរិបទដែលព័ត៌មានក្លែងក្លាយកំពុងវាយលុកបណ្ដាញសង្គម អ្នកប្រើប្រាស់ត្រូវប្រយ័ត្នប្រយែងឲ្យមានខែនមុនពេលដាក់ចិត្តជឿ ឬ ចែករំលែកបន្ត។

- នៅពេលឃើញព័ត៌មានដែលគួរឲ្យសង្ស័យ ពលរដ្ឋមិនត្រូវឆាប់ប្រតិកម្ម ជឿ ឬចែករំលែកភ្លាមៗទេ ដោយត្រូវពិនិត្យពិច័យស្វែងរកប្រភពឲ្យបានច្បាស់លាស់សិន។ ព្រោះព័ត៌មានក្លែងក្លាយ ភាគច្រើនលើសលុបត្រូវបានប្រឌិតឡើងដើម្បីជាប្រយោជន៍សេដ្ឋកិច្ច ឬដើម្បីគេងចំណេញនយោបាយតែប៉ុណ្ណោះ៕

# Thank You!